ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កម្មវិធីបណ្តុះបណ្តាល
# ស្តីពី
# ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប

សម្រាប់ខេត្ត សៀមរាប
ថ្ងៃទី២៧-២៨ ខែកញ្ញា ឆ្នាំ ២០២១
រៀបចំដោយ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# មេរៀនទី ៦ ៖ ការផ្ដល់សេវា

ឯកសារបង្អែក៖ សៀវភៅគោលការណ៍ណែនាំ ស្ដីពីបែបបទនិងនីតិវិធិនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប

រៀបរៀងដោយ ក្រុមការងារបណ្ដុះបណ្ដាល នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ដឹកនាំដោយលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃនៃ គ.ជ.ប.ជ

បទបង្ហាញដោយ៖ លោកអនុសេនីយ៍ឯក **នន់ ឧត្ដម**
នាយរងការិយាល័យ អប់រំផ្សព្វផ្សាយ

# គោលបំណងនៃមេរៀន

- ដើម្បីឲ្យសិក្ខាកាមបានយល់កាន់តែច្បាស់អំពី៖
  - ភាពចាំបាច់និងសារសំខាន់នៃការផ្តល់សេវា ក្នុងការតម្រង់ទិសជួយជនរងគ្រោះនៅពេលត្រឡប់ចូលសហគមន៍វិញ ក៏ដូចជាការវែកមុខជនពាក់ព័ន្ធប្រព្រឹត្តបទល្មើស ដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
  - នីតិវិធីក្នុងការបញ្ជូន ជនសង្ស័យរងគ្រោះដើម្បីទទួលសេវាបន្ត។
  - តួនាទីក្រសួងមន្ទីរនិងអង្គការពាក់ព័ន្ធ ក្នុងការផ្តល់សេវាជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

# ១. សិទ្ធិជនរងគ្រោះ

យោងតាមគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការសិទ្ធិជនរង ដោយអំពើជួញដូរមនុស្សតាមប្រកាសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លេខ៨៥៧ ស.អ.យ ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០០៩ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់កិច្ចការពារ សិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រង់ជំពូកទី ២ប្រការ៦៖ **ស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងសប្បុរសជន ត្រូវគោរពតាមលក្ខខណ្ឌ ស្តីពីសិទ្ធិជនរងគ្រោះ**



# ២ ការផ្តល់សេវាជូនជនរងគ្រោះ

២.១ ប្រភេទសេវា

ក. សេវាបឋម៖

១.សេវាសង្គ្រោះបន្ទាន់

២. សេវាចាំបាច់មូលដ្ឋាន

ខ. សេវាបន្ត

១.សេវាក្នុងមណ្ឌលថែទាំ

២.សេវាក្នុងសហគមន៍

# សំណួរ

.តើអ្វីទៅជាសេវាសង្គ្រោះបន្ទាន់ ?

.តើសេវានេះត្រូវផ្តល់ជូនជនសង្ស័យរងគ្រោះក្នុងលក្ខខណ្ឌណាខ្លះ?

# សេវាសង្គ្រោះបន្ទាន់៖

ក្នុងករណីដែលជនរងគ្រោះស្ថិតក្នុងសភាពជំងឺធ្ងន់ធ្ងរ ឈឺពោះសម្រាលកូន របួសធ្ងន់ធ្ងរ វិបល្លាសស្មារតី...ដែលចាំបាច់ទំនាក់ទំនង និងបញ្ជូនទៅសង្គ្រោះនៅមូលដ្ឋានសុខាភិបាល ដែលនៅជិតបំផុត មុនពេលឬក្នុងអំឡុងពេលដំណើរកំណត់អត្តសញ្ញាណ។



# ចំណុចត្រូវចងចាំ

## សំគាល់៖

ប្រសិនបើជនរងគ្រោះបានបាត់បង់ជីវិត អាស្រ័យដោយស្ថានភាពសុខភាពមិនប្រក្រតី ឬដោយឧប្បត្តិហេតុណាមួយ នៅក្នុងអំឡុងពេលនៃដំណើរការកំណត់អត្តសញ្ញាណ ករណីនេះគប្បីរាយការណ៍ទៅសមត្ថកិច្ច នគរបាលជំនាញជាបន្ទាន់ ដើម្បីបន្តនីតិវិធីរបស់ជំនាញ (ធ្វើកោសល្យវិច័យ ស៊ើបអង្កេត ប្រមូលភស្តុតាង...)។ មានន័យថា ការកំណត់អត្តសញ្ញាណត្រូវបានបង្វែរនីតិវិធីទៅសមត្ថកិច្ចជំនាញ ដើម្បីប្រមូលព័ត៌មាន និងភស្តុតាងពីអ្នកពាក់ព័ន្ធដើម្បីកំណត់បទល្មើសវិញ។



# ២.សេវាបន្ត

.តើសេវាបន្ត ត្រូវធ្វើឡើងនៅពេលណា?

.តើតួរអង្គស្ថាប័នឬអង្គភាពពាក់ព័ន្ធណាខ្លះជាអ្នកផ្តល់សេវាបន្ត ?

# ២.១.សេវាបន្ត(ត)

- បន្ទាប់ពីបានកំណត់អត្តសញ្ញាណនិងកំណត់បានថា ជននោះជាជនសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ជនរងគ្រោះនឹងត្រូវបានបញ្ជូនទៅទទួលសេវាបន្ត នៅឯមូលដ្ឋានតាមសហគមន៍ឬនៅតាមមណ្ឌលផ្តល់សេវានានា តាមការស្នើរសុំរបស់ជនសង្ស័យថារងគ្រោះដែលសមស្របទៅនឹងស្ថានភាពជាក់ស្តែង និងទៅតាមលទ្ធភាពជាក់ស្តែរបស់សេវាករ។

# ២.១.១ សេវានៅមណ្ឌលថែទាំ ៖

- សេវាដែលអាចផ្តល់ជូនជនរងគ្រោះមានជាអាទិ៍៖
  - _ការថែទាំសុខភាពផ្លូវកាយ ផ្លូវចិត្ត
  - _ការផ្តល់ប្រឹក្សា
  - _ការផ្តល់ការស្នាក់នៅបណ្តោះអាសន្ន
  - _ការបណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត
  - _សេវាផ្លូវច្បាប់ ការងារ មុខរបរ ។ល។
- ការសិក្សាអប់រំសម្រាប់កុមារ និងយុវជន។

## ២.១.២សេវាថែទាំនៅសហគមន៍៖

- សហគមន៍គឺជាកន្លែងផ្តល់សេវាដែលទូលំទូលាយបំផុត និងអាចផ្តល់ជូនគ្នា នឹងការថែទាំក្នុងមណ្ឌលដែល ដោយហេតុថា ជនរងគ្រោះអាចនៅជិតស្និតជាមួយគ្រួសារ មិត្តភក្តិ និងមានសេវាជាច្រើនដែលបើកទូលាយក្នុងការផ្តល់ឲ្យពីស្ថានប័នជំនាញពាក់ព័ន្ធវិស័យឯកជន ក៏ដូចជាអង្គការដៃគូនានា ដែលមានសកម្មភាពក្នុងសហគមន៍ផងដែរ។

# វិធានការ ៦ចំណុចៈ

ចំណុចទី២៖ ក្នុងដំណើរការនៃការកំណត់អត្តសញ្ញាណបឋម មិនត្រូវព្យាយាមឲ្យជនដែលសង្ស័យថាជាជនរងគ្រោះ រងការប៉ះទង្គិចលើផ្លូវចិត្ត ឬការខូចខាតផ្សេងៗបន្ថែមទៀតទេ។ ម្យ៉ាងទៀត ជនរងគ្រោះបរទេសដែលត្រូវបានកំណត់អត្តសញ្ញាណជាផ្លូវការ មិនត្រូវបានឃុំខ្លួន ឬចោទប្រកាន់ពីបទសន្ថោប្រវេសន៍ ខុសច្បាប់ សញ្ចារកម្ម ឬពេស្យាចារឡើយ ហើយពួកគេត្រូវទទួលបានជម្រកនិងកិច្ចការពារក្នុងពេលរងចាំដំណើការធ្វើមាតុភូមិនិវត្តិន៍ជាផ្លូវការ ទៅកាន់ប្រទេសខ្លួនវិញ។ ក្នុងករណីនេះចាំបាច់ត្រូវទំនាក់ទំនងទៅស្ថានទូតសាមីដើម្បីអនុវត្តតាមនីតិវិធីច្បាប់។

# វិធានការ៦ចំណុច(ត)

- ចំណុចទី ៤៖ ក្នុងករណីជនរងគ្រោះសញ្ជាតិខ្មែរ ដែលត្រូវបានកំណត់អត្តសញ្ញាណបឋមនៅឯបរទេស ការទទួលសេវា និងការស្នាក់នៅបណ្ដោះអាសន្ន របស់ជនដែលបានកំណត់អត្តសញ្ញាណរួចហើយ ត្រូវចាត់ចែងស្របតាមកិច្ចព្រមព្រៀង រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសពាក់ព័ន្ធ ទាំងនោះ ឬស្របតាមនីតិវិធីច្បាប់ជាធរមាន។ ទោះយ៉ាងណាក៏ដោយ ជនរងគ្រោះកម្ពុជា នៅតែទទួលបានសេវាគាំពារចាំបាច់ផ្សេងៗ ពីស្ថានតំណាងបេសកកម្មការទូត របស់ព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅបរទេស ឬតំបន់នោះ ហើយស្ថានតំណាងបេសកកម្មទូតរបស់ប្រទេសកម្ពុជា ត្រូវរាយការណ៍ជាបន្ទាន់តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទៅក្រសួងមហាផ្ទៃនិងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីសម្របសម្រួលរាល់បែបបទអន្តោប្រវេសន៍ ក្នុងការធ្វើមាតុភូមិនីវត្តន៍ ចាកតចែងការប្រគល់-ទទួលនិងការធ្វើសមាហរណកម្មជនរងគ្រោះតាមនីតិវិធីជាធរមាន។

គ្រប់ករណីទាំងអស់ ស្ថានតំណាងបេសកម្មការទូតរបស់ប្រទេសកម្ពុជា អាចចាត់ចែងសម្របសម្រួល ជាមួយទីភ្នាកងារផ្ដល់សេវាគាំទ្រជនរងគ្រោះ ឬអង្គការជាតិ អន្តជាតិប្រចាំប្រទេសកម្ពុជា ឬប្រទេសគោលដៅឬទីភ្នាក់ងារជ្រើសរើសពលករឯកជនដែលពាក់ព័ន្ធ ដើម្បីផ្ដល់ការគាំទ្រ និងជំនួយសមស្របដល់ជនរងគ្រោះមុនពេល ក្នុងពេល និងក្រោយពេលធ្វើមាតុភូមិនិវត្ត។

# សូមអរគុណ !!